Cambodian Civil Society Strengthening Project

# ការគាំទ្រផ្នែកច្បាប់ដល់អង្គការមិនមែនរដ្ឋាភិបាល / អង្គការសង្គមស៊ីវិល

## គោលការណ៍ណែនាំ ទី ០២

## ស្តីពី

## សិទ្ធិ អត្ថប្រយោជន៍ និងកាតព្វកិច្ចតាមច្បាប់ស្តីពី

## សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ( LANGO )

**សេចក្តីផ្តើម**:

ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ច.ស.អ)ត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១៥ និងប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៥។

(ច.ស.អ) ផ្តោតលើតម្រូវការ និងកាតព្វកិច្ចផ្សេងៗដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវតែប្រកាន់ខ្ជាប់។ ពតិមានណែនាំបន្ថែមអាចរកបាននៅក្នុងគោលការណ៍ណែនាំទី ០១ "ស្តីពីការចុះបញ្ជីតាមច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល(ច.ស.អ)។

គោលការណ៍ណែនាំទី ០២ នេះមានគោលបំណងជួយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលឱ្យយល់កាន់តែច្បាស់អំពីសិទ្ធិ អត្ថប្រយោជន៍ កាតព្វកិច្ច និងទណ្ឌកម្ម សម្រាប់ការអនុវត្តសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលជាប់ពាក់ព័ន្ធទៅនឹងច្បាប់ពន្ធដារ ច្បាប់ការងារ ច្បាប់អន្តោប្រវេសន៍ និងបទបញ្ញត្តិជាធរមានមួយចំនួនទៀតនៅកម្ពុជា។ ច្បាប់ (ច.ស.អ ក៏តម្រូវឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលប្រកាន់ជំហរអព្យាក្រិត្រ ចំពោះគ្រប់គណៈបក្សនយោបាយទាំងអស់។

គោលការណ៍ណែនាំនេះសំដៅទាំងពីរគឺ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

## សំណួរដែលគេតែងតែសួរញឹកញាប់

**១. តើមានតម្រូវការរបាយការណ៍ដែរ ឬទេ?**

មានតម្រូវការរបាយការណ៍ផ្សេងៗ។ យោងតាមគោលការណ៍ណែនាំទី០៣ ដែលមានចំណងជើងថា" គោលការណ៍ណែនាំលេខ ០៣ ស្តីពីការជូនដំណឹងដែលតម្រូវដោយច្បាប់ស្តីពី សមាគម និង អង្គការមិនមែនរដ្ឋាភិបាល។

**២. តើសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាត្រូវជាប់កាតព្វកិច្ចពន្ធដែរ ឬទេ?**

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជី ឬអនុស្សរណៈ ត្រូវស្ថិតនៅក្រោមនីតិរូប នៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានាស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន[1]។

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានទទួលឋានៈលើកលែងពន្ធជាផ្លូវការមាន កាតព្វកិច្ចបង់ពន្ធ[2]។

**៣. តើសមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចចុះកិច្ចសន្យានៅកម្ពុជាបានទេ?**

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជី ឬអនុស្សរណៈ មានសិទ្ធិចុះកិច្ចសន្យាសហប្រតិបត្តិការជាមួយដៃគូ ក្នុងការអនុវត្តគម្រោងសកម្មភាព ស្របតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា[3]។

**៤. តើសមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចជួលកម្មករ ឬបុគ្គលិកក្នុងស្រុក ឬបរទេសបានទេ?**

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជី ឬអនុស្សរណៈ មានសិទ្ធិជ្រើសរើសបុគ្គលិកក្នុងស្រុក ឬបរទេស ដើម្បីបម្រើការងារ ដោយអនុលោមតាមច្បាប់ស្តីពី អន្តោប្រវេសន៍ និងច្បាប់ការងារ និងលិខិតបទដ្ឋានគតិយុត្តិនានានៃព្រះរាជាណាចក្រកម្ពុជា[4]។

ច្បាប់ទាំងនេះតម្រូវឱ្យបុគ្គលិកបរទេសទាំងអស់ មានទិដ្ឋាការការងារ និងប័ណ្ណការងារជនបរទេស សៀវភៅការងារជនបរទេស និងដាក់កម្រឹតឱ្យស្នើសុំកូតា ចំនួនបុគ្គលិកបរទេស ដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចជួលឱ្យធ្វើការ[5]។

---

[1] មាត្រា ២០ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[2] ប្រធានបទ ពន្ធដា និងអត្ថប្រយោជន៍ពន្ធ នឹងត្រូវចែងនៅក្នុងគោលការណ៍ណែនាំដោយឡែក

[3] មាត្រា ២១ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[4] មាត្រា ២២ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[5] ប្រធានបទ កាតព្វកិច្ចការងារ និងអន្តោប្រវេសន៍របស់និយោជិកបរទេស នឹងត្រូវចែងនៅក្នុងគោលការណ៍ណែនាំដាច់ដោយឡែក

**៥. តើមានការកំណត់លក្ខខណ្ឌហាមឃាត់អ្វីខ្លះ ចំពោះ ធនធាន និងទ្រព្យសម្បត្តិ របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល?**

ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានកំណត់នូវប្រភេទធនធាន និងទ្រព្យសម្បត្តិជាក់លាក់ ដែលអាចកាន់កាប់ដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ ប៉ុន្តែមិនបានកំណត់ច្បាស់លាស់សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសទេ។

**ធនធាន និងទ្រព្យសម្បត្តិរបស់សមាគមក្នុងស្រុកមាន:**

- ភាគទាន និងវិភាគទាន ឬបរិវិសទានរបស់សមាជិក
- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់សមាគម
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត

**ធនធាន និងទ្រព្យសម្បត្តិរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមាន:**

- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត[6]

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមានធនធាន និងទ្រព្យសម្បត្តិដូចគ្នានិង សមាគមក្នុងស្រុក ប៉ុន្តែមិនរាប់បញ្ចូលប្រភេទទី ១ ទេពីព្រោះអង្គការមិនមែនរដ្ឋាភិបាលមិនមានសមាជិកទេ។

ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវបានមកពីប្រភពស្របច្បាប់នានា[7]។

**៦. តើ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស មានអភ័យឯកសិទ្ធិការទូតដោយស្វ័យប្រវត្តិដែរ ឬទេ?**

ទីស្នាក់ការតំណាងរបស់ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស បុគ្គលិកបរទេស និងសមាជិកគ្រួសាររបស់ពួកគេ និងបុគ្គលិកក្នុងស្រុកមិនទទួលបានអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិជាអ្នកការទូតដោយស្វ័យប្រវត្តិ ដូចដែលមានចែងក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ ១៩៦១ ស្តីពីទំនាក់ទំនងការទូតឡើយ ទាក់ទងនិងសកម្មភាពបំពេញមុខងាររបស់ខ្លួន និងរឿងក្តីគ្រប់ប្រភេទ។ លើកលែងតែមានកិច្ចព្រមព្រៀងពិសេសរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរ ទេស[8]។

(ច.ស.អ) មិនបានបញ្ជាក់ពីប្រភេទ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល និងកាលៈទេសៈជានានូវ ដែលត្រូវទទួលបានអភ័យឯកសិទ្ធិនោះទេ។

---

[6] មាត្រា ១៨ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[7] មាត្រា ១៩ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[8] មាត្រា ២៣ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

**៧. សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានកាតព្វកិច្ចប្រកាន់ជំហរអព្យាក្រឹតផ្នែកនយោបាយ បើសិនជាមានដូច្នេះមែន តើកាតព្វកិច្ចនេះមានន័យយ៉ាងដូចម្តេច?**

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវប្រកាន់ជំហរអព្យាក្រឹតចំពោះគ្រប់គណបក្សនយោបាយនៅព្រះរាជាណាចក្រកម្ពុជា[9]។

(ច.ស.អ) មិនបញ្ជាក់ថា តើកាតព្វកិច្ច(អព្យាក្រឹតភាព) នេះតម្រូវយ៉ាងណានោះទេ ឬការរំលោភបំពានលើអព្យាក្រឹតភាពយ៉ាងណានោះដែរ (ច.ស.អ) មិនបានដាក់កាតួកិច្ច (អព្យាក្រឹតភាព) នេះចំពោះសមាគមក្នុងស្រុកទេ[10]។

**៨. តើអ្វីទៅជាទណ្ឌកម្ម ចំពោះការមិនបានអនុវត្តតាមកាតព្វកិច្ច របាយការណ៍ ឬអព្យាក្រឹតភាពផ្នែកនយោបាយ ហើយមានឱកាសប្តឹងតវ៉ាចំពោះការសម្រេច ទាំងនោះដែរ ឬទេ?**

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បានផ្តល់កិច្ចការពារច្រើនជាង សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសតាម (ច.ស.អ) ព្រោះពួកគេមានសិទ្ធិប្តឹងតវ៉ាទៅតុលាការ ចំពោះការសម្រេចរដ្ឋបាល និងការដាក់ទណ្ឌកម្មផ្សេង ។

វិធានការណ៍រដ្ឋបាលសម្រាប់ការមិនគោរពតាមតម្រូវការរបាយការណ៍ និងអព្យាក្រឹតភាពផ្នែកនយោបាយមានដូចខាងក្រោម ៖

<u>**សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក**</u>

ក្រសួងមហាផ្ទៃនឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ ដើម្បីឱ្យអនុវត្តតាមច្បាប់។ ប្រសិនបើសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមិនអនុវត្តតាមទេនោះ ក្រសួងមហាផ្ទៃនឹងផ្អាកសកម្មភាពរបស់ សមាគម ឬអង្គការនោះជាបណ្តោះអាសន្នរហូតដល់ **៩០ (កៅសិប)** ថ្ងៃ។ ប្រសិនបើសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុករំលោភបំពានម្តងហើយម្តងទៀត ក្រសួងមហាផ្ទៃអាចបិទទ្វារអង្គការនោះ ដោយលប់ឈ្មោះចេញពីបញ្ជីជាផ្លូវការ[11]។

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលណា ដែលត្រូវបានផ្អាកសកម្មភាពជាបណ្តោះអាសន្ន ឬបានលប់ឈ្មោះចេញពីបញ្ជី ប៉ុន្តែនៅតែបន្តសកម្មភាពនៅក្នុងប្រទេសកម្ពុជា នឹងត្រូវពិន័យជាប្រាក់ពី **៥ (ប្រាំ)** លានរៀលទៅ **១០ (ដប់)** លានរៀល ដោយក្រសួងមហាផ្ទៃ និងអាចប្រឈមមុខនឹងទណ្ឌកម្មផ្នែកច្បាប់ផ្សេងៗផងដែរ[12]។

---

[9] មាត្រា ២៤ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[10] នៅក្នុងការអនុវត្តជាក់ស្តែងកាតព្វកិច្ច អព្យាក្រឹត្យ ត្រូវបានបកស្រាយ ជាការហាមឃាត់ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល មិនឱ្យជួយឬចូលរួមនៅក្នុងគណបក្សនយោបាយនានា។

[11] មាត្រា ៣០ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[12] មាត្រា ៣២ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសិទ្ធិប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ ទាក់ទងនឹងការផ្អាកសកម្មភាព ការលប់ឈ្មោះចេញពីបញ្ជី និងការពិន័យទៅតុលាការក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ចាប់ពីថ្ងៃជូនដំណឹងពីសេចក្តីសម្រេច[13] ។

**<u>សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស</u>**

ដំបូងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ **៣០ (សាមសិប)ថ្ងៃ** ដើម្បីឱ្យអនុវត្តតាមច្បាប់ ។ ប្រសិនបើសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសមិនគោរពតាម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ **៣០ (សាមសិប)ថ្ងៃ**។ ចុងក្រោយករណីមិនអនុវត្តតាមការព្រមាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវសម្រេចជាលាយលក្ខណ៍អក្សរ បញ្ចប់សុពលភាពនៃអនុស្សារណៈ (MoU)[14]។

ប្រសិនបើសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស បន្តធ្វើសកម្មភាពដោយគ្មានអនុស្សរណៈ (MoU) ឬអនុស្សរណៈបញ្ចប់សុពលភាព អាចត្រូវបានបណ្តេញចេញតាមច្បាប់អន្តោប្រវេសន៍របស់ព្រះរាជាណាចក្រកម្ពុជា ឬអាចប្រឈមនឹងការផ្តន្ទាទោសព្រហ្មទណ្ឌផ្សេងៗទៀត[15]។

(ច.ស.អ) មិនបានចែងអំពីការអនុញ្ញាត្តិអោយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស មានសិទ្ធិប្តឹងតវ៉ាទៅតុលាការ នឹងសេចក្តីសម្រេចរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទាក់ទងនឹងការផ្អាកសកម្មភាព ការលប់ឈ្មោះចេញពីបញ្ជី និងការពិន័យនោះទេ ។

**៩. តើមានភាតព្វកិច្ច និងទណ្ឌកម្មអ្វីខ្លះដែលខ្ញុំគួរតែដឹង**?

សមាគម និងអង្គការមិមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនអនុវត្តតាមលក្ខន្តិកៈរបស់ខ្លួន ក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬប្រឈមនឹងការផ្អាកសកម្មភាព ដោយទុករយៈពេល **៣០ (សាមសិប)** ថ្ងៃនៃថ្ងៃធ្វើការ ឬនឹងត្រូវបានលុបឈ្មោះចេញពីបញ្ជី បើនៅបន្តសកម្មភាពមិនគោរពតាមច្បាប់[16]។ ស្រដៀងគ្នានេះដែរ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមិនគោរពតាមអនុស្សរណៈ(MOU) ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាចប្រឈមនឹងការបញ្ចប់សុពលភាពអនុស្សរណៈ[17]។

---

[13] មាត្រា ៣១ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[14] មាត្រា ៣៣ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[15] មាត្រា ៣៤ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[16] មាត្រា ៣០ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[17] មាត្រា ៣៥ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

លើសពីនេះទៀតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ធ្វើសកម្មភាព ដែលប៉ះពាល់ដល់ សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណីនិងទំនៀមទម្លាប់ល្អ របស់សង្គមជាតិកម្ពុជា[18] និងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលចូលរួមក្នុងសកម្មភាពទាំងនេះ នឹងប្រឈមមុខនឹងការលុបឈ្មោះចេញពីបញ្ជី ឬបញ្ចប់អនុស្សរណៈ[19]។

ចុងក្រោយ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬបរទេសណា ដែលសកម្មភាពរបស់ខ្លួនធ្វើអោយប៉ះពាល់ដល់សន្តិសុខជាតិ ឬមានការពាក់ព័ន្ធ និងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌកម្ពុជា[20]។

★★★

**គោលការណ៍ណែនាំនេះ បានធ្វើឡើងដោយមានការឧបត្ថម្ភសប្បុរសធម៌ពី ប្រជាពលរដ្ឋអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ ខ្លឹមសារនៃគោលការណ៍ណែនាំនេះ ជាការទទួលខុសត្រូវរបស់អង្គការ ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា និងមិនឆ្លុះបញ្ចាំងជាចាំបាច់ពីទស្សនៈរបស់ទីភ្នាក់ងារ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។**

---

[18] មាត្រា ៣០ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[19] មាត្រា ៣៥ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

[20] មាត្រា ៣៦ ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល